# បទបង្ហាញ

## ស្ដីពី

# ភាគព្វកិច្ចគណនេយ្យនិងសវនកម្ម

# និងបទប្បញ្ញត្តិពាក់ព័ន្ធ

## សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

រៀបចំដោយ÷ និយ័តករគណនេយ្យនិងសវនកម្ម

ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

# មាតិកានុក្រម

១. ការកាន់បញ្ជីគណនេយ្យ
២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ
៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យត្រូវសវនកម្មឯករាជ្យ
៤. ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក ន.គ.ស.
៥. ពិន័យអន្តរការណ៍
៦. ករណីមិនរាងចាល ឬ ការយឺតយ៉ាវមិនបង់ប្រាក់ពិន័យអន្តរការណ៍
៧. បណ្តឹងតវ៉ា
៨. កម្រៃសេវាសាធារណៈ

# ១. ការកាន់បញ្ជីគណនេយ្យ

## ១.១. បញ្ជីគណនេយ្យ មានជាអាទិ៍ ÷

- ❖ បញ្ជី/ សៀវភៅទិញ
- ❖ បញ្ជី/ សៀវភៅលក់
- ❖ បញ្ជី/ សៀវភៅទទួលប្រាក់
- ❖ បញ្ជី/ សៀវភៅបង់ប្រាក់
- ❖ បញ្ជី/ សៀវភៅចាំបាច់ផ្សេងទៀត...

# ១. ការកាន់បញ្ជីគណនេយ្យ (ត)

## ១.២. ភាសា ÷

❖ បញ្ជីគណនេយ្យ អាចប្រើភាសាអង់គ្លេស ក្នុងករណី ÷

- ប្រព័ន្ធគណនេយ្យកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យជាភាសាអង់គ្លេស។

  ឧទាហរណ៍ ÷ QuickBooks, Peachtree ,Simply Accounting ជាដើម។

- ត្រូវជូនដំណឹងពីការប្រើប្រាស់ភាសាអង់គ្លេសមក ន. គ. ស.

# ១. ការកាន់បញ្ជីគណនេយ្យ (ត)

## ១.២. ភាសា (ត) ÷

❖ ឯកសារគាំទ្រដល់កិច្ចបញ្ជិកាគណនេយ្យ ÷

- ត្រូវជាភាសាខ្មែរ ឬ អាចប្រើភាសាអង់គ្លេសអមជាមួយភាសាខ្មែរបាន => សម្រាប់ឯកសារគណនេយ្យផ្ទៃក្នុង
- អាចជាភាសាអង់គ្លេស => សម្រាប់
  - ឯកសារគណនេយ្យដែលបង្កើតចេញដោយប្រព័ន្ធកុំព្យូទ័រដែលមិនអាចប្រើជាភាសាខ្មែរបាន
  - ឯកសារផ្តល់ដោយដៃគូធុរកិច្ចបរទេស ឬ សម្រាប់ធុរកិច្ចជាមួយដៃគូបរទេស ។
- ចំពោះឯកសារគាំទ្រការធ្វើធុរកិច្ច ឬប្រតិបត្តិការក្រៅពីភាសាខ្មែរ និងភាសាអង់គ្លេសត្រូវបកប្រែឯកសារទាំងនោះជាភាសាខ្មែរឬភាសាអង់គ្លេស។

# ១. ការកាន់បញ្ជីគណនេយ្យ (ត)

## ១.៣. រូបិយបណ្ណ ÷

- ❖ អាចជ្រើសរើស រូបិយបណ្ណមុខងារជាប្រាក់រៀល ឬ មិនមែនជាប្រាក់រៀលតាមគោលនយោបាយគណនេយ្យរបស់ខ្លួន។

## ១.៤. ការិយបរិច្ឆេទគណនេយ្យ ÷

- ❖ រយៈពេល ១២ ខែ គិតចាប់ពី ថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល
- ❖ អង្គភាពថ្មី (គិតចាប់ផ្តើមពីថ្ងៃបង្កើត ដល់ថ្ងៃទី៣១ ខែ ធ្នូ នៃឆ្នាំដដែល)
- ❖ ការិយបរិច្ឆេទគណនេយ្យកំណត់ផ្សេងពីនេះៗ សម្រាប់សកម្មភាពដែលមានលក្ខណៈពិសេស ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៥......សហវ.......

ថ្ងៃ [illegible] ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ២០២១

**សារាចរណែនាំ**
**ស្តីពី**
**ការប្រើប្រាស់ភាសា និង រូបិយប័ណ្ណ**
**ក្នុងបញ្ជីគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុ**

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងក្នុងគោលបំណងសម្រួលដល់ការធ្វើធុរកិច្ចរបស់ធុរជនដោយអាចរក្សាបានគុណតម្លៃនៃភាសាខ្មែរ និងប្រាក់រៀលព្រមទាំងអាចធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំ ដូចខាងក្រោម÷

១-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចប្រើភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យ ក្នុងករណីដែលសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញពុំទាន់អាចរកបានប្រព័ន្ធកុំព្យូទ័រទាំងនោះ ដែលអាចប្រើភាសាខ្មែរបានតាមតម្រូវការប្រតិបត្តិការរបស់ខ្លួន។ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញពុំបានតម្រូវឱ្យស្នើសុំលើការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធកុំព្យូទ័រទាំងនោះឡើយ ប៉ុន្តែសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវជូនដំណឹងជាលាយល័ក្ខអក្សរមក**និយ័តករគណនេយ្យនិងសវនកម្ម** ដោយបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះ និងប្រភពនៃប្រព័ន្ធកុំព្យូទ័រដែលកំពុងប្រើនោះ។

២-ឯកសារគណនេយ្យផ្ទៃក្នុងដែលគាំទ្រដល់កិច្ចបញ្ជិកាគណនេយ្យ ត្រូវជាភាសាខ្មែរ។ ឯកសារទាំងនេះ អាចត្រូវ បានអនុញ្ញាតឱ្យប្រើភាសាអង់គ្លេសអមជាមួយភាសាខ្មែរបាន។ ចំពោះឯកសារគណនេយ្យដែលបង្កើតចេញពីប្រព័ន្ធកុំព្យូទ័រដែលមិនអាចប្រើភាសាខ្មែរបានដូចមានចែងក្នុងចំណុចទី ១ខាងលើ និងឯកសារគណនេយ្យដែលត្រូវបានរៀបចំ និងផ្តល់ដោយ ដៃគូធុរកិច្ចបរទេស ឬដោយអង្គការដៃគូ ឬម្ចាស់ជំនួយបរទេស ឬសម្រាប់ធុរកិច្ចជាមួយដៃគូធុរកិច្ចបរទេស ឯកសារទាំងនោះអាចជាភាសាអង់គ្លេសបាន។ ក្នុងករណីឯកសារគាំទ្រការធ្វើធុរកិច្ច ឬប្រតិបត្តិការក្រៅពីភាសាខ្មែរ និងភាសាអង់គ្លេស សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវទទួលខុសត្រូវបកប្រែឯកសារទាំងនោះទៅជាភាសាខ្មែរ ឬភាសាអង់គ្លេស ដោយមានប្រថាប់ត្រារបស់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញផ្ទាល់។

<u>ឧទាហរណ៍</u>÷ កិច្ចសន្យាទិញ-លក់ដែលត្រូវបានរៀបចំជាភាសាបរទេស (ក្រៅពីភាសាអង់គ្លេស) ដូចនេះ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវបកប្រែកិច្ចសន្យានោះជាភាសាខ្មែរ ឬភាសាអង់គ្លេស ដោយមាន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ហត្ថលេខាទទួលស្គាល់លើខ្លឹមសារនៃអត្ថបទបកប្រែរបស់ម្ចាស់សហគ្រាស ឬអ្នកមានសិទ្ធិ និងមានប្រថាប់ត្រារបស់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញផ្ទាល់។

៣-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចជ្រើសរើសរូបិយប័ណ្ណមុខងារជាប្រាក់រៀល ឬរូបិយប័ណ្ណបរទេសតាមគោលនយោបាយគណនេយ្យរបស់ខ្លួនដោយអនុលោមតាមស្តង់ដាគណនេយ្យជាធរមាន សម្រាប់កត់ត្រាប្រតិបត្តិការគណនេយ្យប្រចាំថ្ងៃ។

៤-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជាភាសាខ្មែរ និងបង្ហាញជាប្រាក់រៀល ឬបង្ហាញជាប្រាក់រៀលផងនិងរូបិយប័ណ្ណបរទេសផង។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជាប្រាក់រៀល សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវអនុវត្តតាមការណែនាំក្នុងស្តង់ដាគណនេយ្យជាធរមាន ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការដែលបានបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា ហើយត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនោះ មកនិយ័តករគណនេយ្យនិងសវនកម្ម តាមសេចក្តីណែនាំរបស់ និយ័តករគណនេយ្យនិងសវនកម្មដើម្បីជាកម្មវត្ថុនៃការរក្សាទុក និងការត្រួតពិនិត្យលើកម្រិតអនុលោមភាព ស្របតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

៥-ចំពោះសហគ្រាសដែលធ្វើប្រតិបត្តិការប្រេងកាតនៅក្នុងដែនអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមប្រកាស ៥៣៦ សហវ.ប្រក ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការណែនាំអនុវត្តបទប្បញ្ញត្តិស្តីពី ពន្ធលើប្រតិបត្តិការប្រេងកាត។

៦-ក្នុងអំឡុងពេលនៃការអនុវត្តសារាចរនេះ និយ័តករគណនេយ្យនិងសវនកម្ម ត្រូវពិនិត្យ តាមដាន និងវាយតម្លៃលើលទ្ធភាពនៃការកាន់បញ្ជីគណនេយ្យជាភាសាខ្មែរ និងប្រាក់រៀល ។

៧- និយ័តករគណនេយ្យនិងសវនកម្ម អាចស្នើឡើងនូវវិធានចាំបាច់នានាបន្ថែមសម្រាប់ការអនុវត្តសារាចរនេះ។

ទទួលបានសារាចរណែនាំនេះ និយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកដ្ឋានពន្ធដារ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ស្ថាប័នពាក់ព័ន្ធ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវសហការអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ តទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**[illegible]ក្រសួង[illegible]សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល ÷</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

❖ ស្តង់ដាគណនេយ្យ ៖

- អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវប្រើប្រាស់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ CFRS For NFPEs ឬ
- អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលកំពុងប្រើ ឬ មានការតម្រូវការប្រើស្តង់ដាគណនេយ្យ CIFRS ឬ CIFRS for SMEs

## CFRS For NFPEs




## CIFRS For SMEs







## CIFRS









# ២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

- ភាសា៖ ត្រូវតែជាភាសាខ្មែរ។
- រូបិយបណ្ណ៖ ត្រូវតែជាប្រាក់រៀល ឬ (រៀល+រូបិយបណ្ណបរទេស)

- **កាតព្វកិច្ចផ្សេងទៀត ៖**
  - រក្សាទុកក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ គិតពីកាលបរិច្ឆេទនៃការបង្កើតឯកសារ
  - *ធ្វើជាមូលដ្ឋានសម្រាប់បំពេញកាតព្វកិច្ចសារពើពន្ធ ។*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ.០០០១/២៣.....ន. គ. ស /សារ.ស.ណ.

# សេចក្តីជូនដំណឹង

## ស្តីពី

## អត្រាប្តូរប្រាក់សម្រាប់ប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០២២

**អត្រាប្តូរប្រាក់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២÷ ១ ដុល្លារអាមេរិក = ៤ ១១៧ រៀល**

**អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ២០២២÷ ១ ដុល្លារអាមេរិក = ៤ ០៨៧ រៀល**

ថ្ងៃអង្គារ ១២ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣

**និយ័តករគណនេយ្យនិងសវនកម្ម**

*សំគាល់÷ ចំពោះសហគ្រាស ឬ អង្គភាពដែលប្រើរូបិយប័ណ្ណមុខងារខុសពីប្រាក់ដុល្លារសហរដ្ឋអាមេរិក សូមធ្វើការគណនាអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ ដោយយកអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃជារូបិយប័ណ្ណនោះដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា បូកបញ្ចូលគ្នា គិតចាប់ពីកាលបរិច្ឆេទបើកបញ្ជីគណនេយ្យ រហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៃការិយបរិច្ឆេទគណនេយ្យរបស់សហគ្រាស ឬ អង្គភាព រួចចែកនឹង ៣៦៥ ថ្ងៃ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ៨៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

# ៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មឯករាជ្យ

❖ រយៈពេលបញ្ចប់ការងារធ្វើសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យមិនឱ្យហួសរយៈពេល៦ (ប្រាំមួយ) ខែ គិតចាប់ពីការិយបរិច្ឆេទបិទបញ្ជីគណនេយ្យ។

❖ **លក្ខខណ្ឌ ÷**

- អង្គភាពមិនស្វែងរកប្រាក់ចំណេញរងសវនកម្មឯករាជ្យស្ថិតក្នុងលក្ខណៈវិនិច្ឆ័យទាំងពីរខាងក្រោម÷
  ១. ចំណាយសរុបប្រចាំឆ្នាំ លើសពី ២ ០០០ ០០០ ០០០ រៀល និង
  ២. ចំនួនកម្មករនិយោជិត ២០ នាក់ឡើងទៅ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

ថ្ងៃសុក្រ ១២ កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែតុលា ឆ្នាំ២០២២

**សេចក្តីជូនដំណឹង**
**ស្តីពី**
**បច្ចុប្បន្នភាពនៃបញ្ជីក្រុមហ៊ុនដែលទទួលបាននីតិសម្បទាផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ និង សវនកម្ម**

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ ដើម្បីជួយសម្រួលដល់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញក្នុងការជ្រើសរើសក្រុមហ៊ុនគណនេយ្យ ឬ ក្រុមហ៊ុនសវនកម្ម សម្រាប់ការផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ ឬ សេវាវិជ្ជាជីវៈសវនកម្ម និយ័តករគណនេយ្យនិងសវនកម្ម សូមផ្តល់ជូននូវបញ្ជីឈ្មោះក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យ និងក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្ម ដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករគណនេយ្យនិងសវនកម្ម គិតត្រឹមថ្ងៃជូនដំណឹងនេះ មានដូចខាងក្រោម៖

**I. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ**

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាអក្សរឡាតាំង | សេចក្តីសម្រេចលេខ | កាលបរិច្ឆេទផុតសុពលភាព |
|---|---|---|---|---|
| ១ | 3អេស ខនសាល់ធីង ឯ.ក | 3S Consulting Co., Ltd | ០១៦០ សសរ ន.គ.ស. | ៣១-កក្កដា-២០២៣ |
| ២ | វីឌីប៊ី ឡូយ លីមីធីត | VDB Loi Limited | ០១៥០ សសរ គ.ជ.គ. | ៣១-ធ្នូ-២០២២ |
| ៣ | អេ-អិចសឺឡិន ខនសាល់ធេនស៊ី ឯ.ក | A-Xcellent Consultancy Co., Ltd | ០០១៤៥ សសរ គ.ជ.គ. | ៣១-តុលា-២០២២ |
| ៤ | ហុងហ្គោ ស៊ូជីតាក់ & អ៊ីខោនធីង (ខេមបូឌា) | Hongo Tsuji Tax & Accounting (Cambodia) Co., Ltd | ០១៦៨ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៥ | ខ្វន ធឹម & ស្ពេកត្រឹម ឯ.ក | QUATUM & SPECTRUM CO.,LTD | ០០១៨ សសរ ន.គ.ស | ២៦-មេសា-២០២៤ |
| ៦ | អាខ្លែម(ខេមបូឌា) ឯ.ក | ACCLIME (CAMBODIA) CO.,LTD | ០២៩ ន.គ.ស.ស.ស.រ | ១៧-មិថុនា-២០២៤ |
| ៧ | ឡាប៉េ ខេអេច អឌីធីង& ខនសាល់ធីង ឯ.ក | LA PAIX KH AUDITING &CONSULTING CO.,LTD | ០២៧ ន.គ.ស.ស.ស.រ | ១០-មិថុនា-២០២៤ |
| ៨ | ស្កាយ លីមីធីត អ៊ីខោនធីង (ខេមបូឌា)ខូអិធីឌី | Sky Limited Accounting (Cambodia) Co., Ltd | ០៣៣ ន.គ.ស.ស.ស.រ | ៣០-មិថុនា-២០២៤ |

**II. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម**

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាអក្សរឡាតាំង | សេចក្តីសម្រេចលេខ | កាលបរិច្ឆេទផុតសុពលភាព |
|---|---|---|---|---|
| ១ | ប៊្លូ ឆាធើរ អ៊ីខោនថិន អេន អឌីតធ័រ ឯ.ក | Blue Chartered Accountants and Auditors Co., Ltd | ០១៧ ន.គ.ស./សសរ | ១២-មេសា-២០២៤ |
| ២ | អ៊ីស្ត វីង អឌីធីង & ខនសាល់ធីង | East Wing Auditing & Consulting Co., Ltd | ០១៥៩ សសរ ន.គ.ស. | ៣១-កក្កដា-២០២៣ |
| ៣ | វីប៊ីធី អេន ផាតនើរ ឯ.ក | VBT and Partners Co., Ltd | ០១៥៧ សសរ ន.គ.ស. | ៣១-ឧសភា-២០២៣ |
| ៤ | ទ្រីណីធី ប្រ៊ីហ្វេសិនណល | Trinity Professional Co., Ltd | ០១៥៥ សសរ ន.គ.ស. | ៣០-មេសា-២០២៣ |
| ៥ | អេកូវីស វីអេសឌីខេ & ផាតនើរ ឯ.ក | ECOVIS VSDK & Partner Co., Ltd | ០១៥៣ សសរ គ.ជ.គ. | ៣១-មីនា-២០២៣ |
| ៦ | ភី អេ ធីប្រ៊ីហ្វេសិនណលលីមីធីត | P A T Professional Limited | ០១៥២ សសរ គ.ជ.គ. | ២៨-កុម្ភៈ-២០២៣ |
| ៧ | ខេម អ៊ីខោនធីង & ថាក់ សឺវីស ឯ.ក | Cam Accounting & Tax Service Company Limited | ០១៥៤ សសរ គ.ជ.គ. | ២៨-កុម្ភៈ-២០២៣ |
| ៨ | អេស អិម គ្លូបិល អ៊ីខោនធីង & ខនសាលធីង | SM Global Accounting & Consulting Co., Ltd | ០០១៥០ សសរ គ.ជ.គ. | ៣១-ធ្នូ-២០២២ |
| ៩ | អាត្លាស ខនសាល់ធីង ឯ.ក | Atlas Consulting Co., Ltd | ០០១៤៦ សសរ គ.ជ.គ. | ៣១-តុលា-២០២២ |
| ១០ | ផេក ខនសាល់ធីង ឯ.ក | PAC Consulting Company limited | ០៣៩ ន.គ.ស.ស.ស.រ | ១០-កញ្ញា-២០២៤ |
| ១១ | អេធីអេភី &ផាតនើរ ឯ.ក | ATAP & Partners Company Limited | ០៣៧ ន.គ.ស.ស.ស.រ | ៣១-សីហា-២០២៤ |
| ១២ | ហ្វូរមី & ផាតនើរ ឯ.ក | Fourmi & Parners Co., Ltd | ០៣៤ ន.គ.ស.ស.ស.រ | ១-សីហា-២០២៤ |
| ១៣ | រីចង់ & ផាតនើរ | Reachs & Partners Co., Ltd | ០៣១ ន.គ.ស.ស.ស.រ | ៣១-កក្កដា-២០២៤ |
| ១៤ | ហ្វូណន ខនសាល់ធីង ឯ.ក | Funan Consulting Co., Ltd | ០៣០ ន.គ.ស.ស.ស.រ | ៩-កក្កដា-២០២៤ |
| ១៥ | អេសស៊ីអេស គ្លូបិល ខនសាល់ធីង (ខេមបូឌា) | SCS Global Consulting (Cambodia) Co., Ltd | ០៣៥ន.គ.ស.ស.ស.រ | ០៩-កក្កដា-២០២៤ |
| ១៦ | ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី | Deloitte (Cambodia) Co., Ltd | ០២៣ ន.គ.ស.ស.ស.រ | ៣០-មេសា-២០២៤ |
| ១៧ | វី ឆាធើរ អ៊ីខោនថិន | V Chartered Accountants Co., Ltd | ០២៥ ន.គ.ស. | ១០-មេសា-២០២៤ |
| ១៨ | អ៊ីផូឡូ អ៊ិនវេសម៉ិន &ខនសាល់ធីង ឯ.ក | Apollo Investment & Consulting Co., Ltd | ០២៤ន.គ.ស.ស.ស.រ | ៣១-មីនា-២០២៤ |
| ១៩ | ម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក | Morisonkak MKA audit- accounting Co., Ltd | ០២០ ន.គ.ស.សសរ | ៣១-មីនា-២០២៤ |
| ២០ | ចន្ទ & អ៊ីសូស៊ីអេត | Chan & Associates Co., Ltd | ០២៨ ន.គ.ស.ស.ស.រ | ២៨-កុម្ភៈ-២០២៤ |
| ២១ | អាល់នីសុន អឌីធីង អេន ខនសាល់ធីង | Allnison Auditing and Consulting Co., Ltd | ០២២ ន.គ.ស.ស.ស.រ | ២៨-កុម្ភៈ-២០២៤ |
| ២២ | ប្រាយវ៉តធ័រ ហោវខូភើស៍ (ខេមបូឌា) | PricewaterhouseCoopers (Cambodia) Ltd | ០១៦៧ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ២៣ | ខេ ភី អឹម ជី ខេមបូឌា | KPMG Cambodia Ltd | ០១៦៤ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ២៤ | ហ្វីដេស សឺវីស (ខេមបូឌា) លីមីធីត | FIDES Services Cambodia Ltd | ០០១០ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ២៥ | អិន អេ អេស | NAS Co., Ltd | ០១៦៣ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ២៦ | អ៊ីនស៍ អែន យ៉ាំង (ខេមបូឌា) | Ernst & Young (Cambodia) Ltd | ០០៨ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ២៧ | វ៉ូរី អេខោនធីង ខូ អិលធីឌី | Woori Accounting Co., Ltd | ០១៩ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ២៨ | រ៉ូសូខូ លីមីធីត | Rosoco Ltd | ០១៦៩ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ២៩ | អិល អ អេស ហេនឌើសិន (ខេមបូឌា) | LRS Henderson (Cambodia) Co., Ltd | ០១៦៦ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣០ | ដូណាស្កូ & ខមភេនី អិលធីឌី | Donasco & Company., Ltd | ០០៣ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣១ | បេក ឃើរ ធីលលី (ខេមបូឌា) ឯ.ក | Baker Tilly Cambodia Co., Ltd | ០០១៣ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣២ | ក្រូវ (ខេអេច) ឯ.ក | Crowe (KH) Co., Ltd | ០០៧ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
Phone: 023 [illegible]

| | | | | |
|---|---|---|---|---|
| ៣៣ | វិនដា អិល អិល ខេ ជី (ខេមបូឌា) | Reanda LLKG (Cambodia) Co., Ltd | ០២១ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣៤ | ប៊ី ឌី អូ (ខេមបូឌា) លីមីធីត | BDO (Cambodia) Limited | ០១៦៥ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣៥ | អេនឌ្រូ & ហ្វីលីព អ៊ីខោនធីង | Andrew & Philip Accounting Co., Ltd | ០០៩ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣៦ | ខូវេណិនថ៍ អិលធីឌី | Covenant Ltd | ០០១ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣៧ | ប៊ីជី អាសូស៊ីអ៊ីត | BG Associates Ltd | ០០៥ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣៨ | អេភីវី (ខេមបូឌា) ខូ អិលធីឌី | APV (Cambodia) Co., Ltd | ០០២ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៣៩ | អេធី & អាសូស៊ីអេត | AT & Associates | ០២៦ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៤០ | ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត | Grant Thornton (Cambodia) Ltd | ០០៤ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៤១ | ខេ ប្រូហ្វេស៊ិនណល អ៊ីខោនថិន | K Professional Accountants Co., Ltd | ០១៦២ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៤២ | សឡូម៉ុន អ៊ីខោនធីង & ខនសាល់ធីង | Solomon Accounting & Consulting Co.,Ltd | ០០១១ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៤៣ | អេហ្វអាយអាយ & អ៊ីសូស៊ីអេត | Fii & Associates Co., Ltd | ០០៦ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៤៤ | ឡូចន្ទ & ខូ (ខេមបូឌា) ឯ.ក | Lochan & Co (Cambodia) Company Limited | ០១៦ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៤៥ | ថៃ អេន ឡោ មេនេចម៉ិន ខនសាល់ធេន ឯ.ក | Thai and Lor Management Consultant Co., Ltd | ០០១២ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៤៦ | អែតវ៉ាន់ស៍ ហ្គ្រេន ហ្វ័រម៉ូឡា ឯ.ក | ADVANCE GRAND FORMULA CO.,LTD | ០១៤ ន.គ.ស.ស.ស.រ | ៣១-ធ្នូ-២០២៣ |
| ៤៧ | ញូសាញ ខន សាល់ធីង ឯ.ក | NEW SHINE CONSULTING CO.,LTD | ០៣២ ន.គ.ស.ស.ស.រ | ២៧-កក្កដា-២០២៤ |
| ៤៨ | យ៉ុងអាន អ៊ិនធើនេសិនណល ខនសាល់ធីង ឯ.ក | Yongan International Consulting Co.,Ltd | ០៣៦ ន.គ.ស.ស.ស.រ | ១៤-សីហា-២០២៤ |

**បញ្ជាក់៖**

១. ក្រុមហ៊ុនក្នុងចំណុច I ខាងលើ ពុំមានសិទ្ធិផ្តល់សេវាវិជ្ជាជីវៈសវនកម្មឡើយ។

២. ក្រុមហ៊ុនក្នុងចំណុច II ខាងលើ មានសិទ្ធិជាស្វ័យប្រវត្តិក្នុងការផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ។

៣. ក្រុមហ៊ុនគណនេយ្យ ឬ សវនកម្ម ទាំងឡាយណាដែលពុំមានអាជ្ញាបណ្ណពីនិយ័តករគណនេយ្យនិងសវនកម្ម ត្រូវបានហាមឃាត់ក្នុងការផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ ឬ/និង សវនកម្ម។

៤. ក្រុមហ៊ុនដែលបានកំពុងរៀបចំនីតិវិធីស្នើសុំបន្ត ហើយមិនទាន់ចេញសេចក្តីសម្រេចពី ន.គ.ស. នឹងជូនដំណឹងនៅពេលក្រោយ។

និយ័តករគណនេយ្យនិងសវនកម្មនឹងធ្វើបច្ចុប្បន្នភាពឈ្មោះក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យនិងក្រុមហ៊ុនសវនកម្មជាបន្តបន្ទាប់ជូនម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជន ដើម្បីជ្រាបជាព័ត៌មាន។

សម្រាប់ព័ត៌មានបន្ថែម សូមអញ្ជើញមកកាន់ទីស្នាក់ការនិយ័តករគណនេយ្យនិងសវនកម្ម ដែលមានអាសយដ្ឋានស្ថិតនៅផ្លូវ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ អគារ (ក) ជាន់ទី១ (ក្នុងបរិវេណទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ឬទាក់ទងតាមទូរស័ព្ទលេខ: ០៩៦ ២២២២ ៦៥៩ ឬអ៊ីមែល: S.soem@acar.gov,kh។

អាស្រ័យហេតុនេះសូមម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់
និយ័តករគណនេយ្យនិងសវនកម្ម

# ៤. ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

❖ កាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** ៖

- អង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្មឯករាជ្យ មានកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ប្រចាំឆ្នាំមក ន.គ.ស. មិនឱ្យហួសរយៈពេល ៣ខែ ១៥ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

- អង្គភាពមិនស្វែងរកប្រាក់ចំណេញរងសវនកម្មឯករាជ្យ មានកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ដាក់រងសវនកម្មឯករាជ្យរួចមក ន.គ.ស. មិនឱ្យហួសរយៈពេល ៦ខែ ១៥ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...០៣៥៤......ន. គ. ស /.....

ថ្ងៃអង្គារ ៥កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០២២

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការរំលឹកអំពីការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងកាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ មកនិយ័តករគណនេយ្យនិងសវនកម្ម**

**និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អ.ស.ហ.)** មានកិត្តិយស សូមជម្រាបជូនដល់ **ម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ** ជ្រាបថា÷អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវអនុវត្តកាតព្វកិច្ចជាសារវន្តចំនួន ៣(បី) ដូចខាងក្រោម÷

**១. កាន់បញ្ជីគណនេយ្យ ឱ្យបានត្រឹមត្រូវ**

**២. រៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ឱ្យបានរួចរាល់ក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ**

**៣. ដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ដោយត្រូវបញ្ចប់ការងារធ្វើសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ មិនឱ្យហួសរយៈពេល៦ (ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ សម្រាប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលជាប់លក្ខខណ្ឌនៃការអនុវត្តកាតព្វកិច្ចសវនកម្មឯករាជ្យ ដូចមានចែងក្នុងប្រកាសលេខ៥៦៣សហវ.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។**

ជាមួយគ្នានេះដែរ យោងតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម **គ្រប់សហគ្រាសទាំងអស់ និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មានកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមក ន.គ.ស. តាមពេលកំណត់** ទៅតាមប្រភេទសហគ្រាស ឬ អង្គភាពមិនស្វែងរកប្រាក់ចំណេញ។ ដើម្បីឱ្យការអនុវត្តកាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២២ មក **ន.គ.ស.** ទទួលបានជោគជ័យ និងបានទាន់ពេលវេលា គ្រប់សហគ្រាស **(លើកលែងសហគ្រាសអ្នកជាប់ពន្ធតូច)** និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវគោរពតាមការណែនាំដូចខាងក្រោម÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៨៩ - ២៣ ៨៨២ ១១១
Phone: 023 882 111

**១. សហគ្រាស**

**១.១. សហគ្រាសមិនរងសវនកម្មឯករាជ្យ**

ក. ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសរយៈពេល**៣** (បី)ខែ និង**១៥** (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

ខ. ត្រូវដាក់លិខិតស្នើសុំផ្លាស់ប្តូរលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ (FIN) ពីសហគ្រាសមិនរងសវនកម្មឯករាជ្យ ទៅជាសហគ្រាសរងសវនកម្មឯករាជ្យ មក **ន.គ.ស.** មិនឱ្យហួសរយៈពេល**៦០** (ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ករណីសហគ្រាសនោះ ត្រូវបានជាប់លក្ខខណ្ឌរងសវនកម្មឯករាជ្យសម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២២។

**១.២. សហគ្រាសរងសវនកម្មឯករាជ្យ**

ក. ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យរួច មក **ន.គ.ស.** មិនឱ្យហួសរយៈពេល **៦** (ប្រាំមួយ)ខែ និង**១៥** (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

ខ. ត្រូវដាក់លិខិតស្នើសុំផ្លាស់ប្តូរលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ (FIN) ពីសហគ្រាសមិនរងសវនកម្មឯករាជ្យ ទៅជាសហគ្រាសរងសវនកម្មឯករាជ្យ មក **ន.គ.ស.** មិនឱ្យហួសរយៈពេល**៦០** (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ សម្រាប់សហគ្រាសដែលស្ម័គ្រចិត្តដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យរួច មក **ន.គ.ស.** តាមបែបបទ និងនីតិវិធីដូចសហគ្រាសរងសវនកម្មឯករាជ្យដែរ។

**២. អង្គភាពមិនស្វែងរកប្រាក់ចំណេញ ហៅកាត់ថា "អង្គភាព"**

**២.១. អង្គភាពមិនរងសវនកម្មឯករាជ្យ**

ក. ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសរយៈពេល**៣** (បី)ខែ និង**១៥** (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

ខ. ត្រូវដាក់លិខិតស្នើសុំផ្លាស់ប្តូរប្រភេទអង្គភាពពីអង្គភាពមិនរងសវនកម្មឯករាជ្យ ទៅជាអង្គភាពរងសវនកម្មឯករាជ្យ មក **ន.គ.ស.** មិនឱ្យហួសរយៈពេល**៦០** (ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ករណីអង្គភាពនោះ ត្រូវបានជាប់លក្ខខណ្ឌរងសវនកម្មឯករាជ្យសម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២២។

**២.២. អង្គភាពរងសវនកម្មឯករាជ្យ**

ក. ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យរួចមក **ន.គ.ស.** មិនឱ្យហួសរយៈពេល **៦**(ប្រាំមួយ)ខែ និង**១៥**(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ សម្រាប់អង្គភាពដូចមានចែងក្នុងប្រការ៦ នៃប្រកាសលេខ៥៦៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។

ខ. ត្រូវដាក់លិខិតស្នើសុំផ្លាស់ប្តូរប្រភេទអង្គភាព ពីអង្គភាពមិនរងសវនកម្មឯករាជ្យ ទៅជាអង្គភាពរងសវនកម្មឯករាជ្យមក **ន.គ.ស.** មិនឱ្យហួសរយៈពេល**៦០** (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ សម្រាប់អង្គភាពដែលស្ម័គ្រចិត្តដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យរួច មក **ន.គ.ស.** តាមបែបបទ និងនីតិវិធីដូចអង្គភាពរងសវនកម្មឯករាជ្យ។

**៣.ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញ**

សហគ្រាស ឬ អង្គភាព ត្រូវប្រើប្រព័ន្ធអនឡាញ(E-Filing System)របស់ **ន.គ.ស.** ដើម្បីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.**។

សហគ្រាស ឬ អង្គភាព ត្រូវបង់កម្រៃសេវាសាធារណៈសម្រាប់ការទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុស្របតាមប្រកាសលេខ ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

***សហគ្រាស ឬ អង្គភាព ដែលខកខានមិនបានអនុវត្តកាតព្វកិច្ចខាងលើ ត្រូវរងទោសទណ្ឌដូចមានចែងនៅក្នុងអនុក្រឹត្យលេខ៧៩អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។***

**លើសពីនេះទៅទៀត សហគ្រាស ឬ អង្គភាព ដែលខកខានមិនបានអនុវត្តកាតព្វកិច្ចខាងលើរយៈពេលពីរឆ្នាំជាប់ៗគ្នាឡើងទៅ ត្រូវបានចាត់ទុកជាករណីមិនរាងចាល។**

**ន.គ.ស. នឹងអាចចុះត្រួតពិនិត្យដល់ទីស្នាក់ការ ឬ ការិយាល័យរបស់សហគ្រាស និងអង្គភាព តាមការចាំបាច់ដោយអនុលោមតាមច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមន្ត្រីរបស់ ន.គ.ស. តាមរយៈប្រព័ន្ធតេឡេក្រាមដូចខាងក្រោម៖**

- សហគ្រាសរងសវនកម្មឯករាជ្យ៖ ០៧០ ៩២៩ ២៣៧/ ០១០ ៧៣៦ ៨៣៥/ ០១០ ៧៧១ ៥៦៨
- សហគ្រាសមិនរងសវនកម្មឯករាជ្យ៖ ០៩៣ ៩១៩ ១៩២/ ០៧០ ៥៤៥ ៦៨៨/ ០៨៩ ៥០៨ ៥៦៧
- អង្គភាព៖ ០៨១ ៦៤៤ ៦៦៣/ ០៨៥ ៤៤៤ ៤៨៨/ ០៨៩ ៥០៨ ៥៦៧
- អ្នកទទួលបន្ទុករួម៖ ០១០ ៣០៩ ២០០ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាព មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពនិងប្រកបដោយការទទួលខុសត្រូវខ្ពស់ចាប់ពីពេលនេះតទៅ។

**អគ្គនាយក**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម

**ប៊ូ ថារិន**

# ៥. ពិន័យអន្តរការណ៍

❖ អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលខកខានមិនបានអនុវត្តកាតព្វកិច្ចខាងលើ ត្រូវរងទោសទណ្ឌដូចមានចែងក្នុង *អនុក្រឹត្យលេខ ៧៩ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ។*

# ៦. ករណីមិនរាងចាល និងការយឺតយ៉ាវមិនបង់ប្រាក់ពិន័យអន្តរការណ៍

## ៦.១. ករណីមិនរាងចាល ៖

❖ ក្នុងករណីមិនរាងចាល បុគ្គលល្មើសត្រូវទទួលរងការពិន័យអន្តរការណ៍បន្ថែមជាប្រាក់ដូចខាងក្រោម៖

- មិនរាងចាលលើកទី១ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍គុណនឹងពីរដងនៃប្រាក់ពិន័យអន្តរការណ៍ដែលបង់លើកដំបូង
- មិនរាងចាលលើកទី២ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍គុណនឹងពីរដងនៃប្រាក់ពិន័យអន្តរការណ៍ដែលបង់ក្នុងករណីមិនរាងចាលលើកទី១
- មិនរាងចាលលើកទី៣ **ន.គ.ស.** នឹងរៀបចំលិខិតស្នើសុំទៅក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីចាត់វិធានការស្របតាមច្បាប់ជាធរមានចំពោះសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

# ៦. ករណីមិនរាងចាល និងការយឺតយ៉ាវមិនបង់ប្រាក់ពិន័យអន្តរការណ៍

## ៦.២ ការយឺតយ៉ាវមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ ៖

❖ ក្នុងករណីបុគ្គលល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍៖

- ក្នុងរយៈពេល ៣០ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង
- លើសពី ៦០ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នេះនឹងត្រូវដំឡើងជាបីដង
- ផុតរយៈពេល ៩០ថ្ងៃ ន.គ.ស. នឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

**ចំណាំ៖** រយៈពេល ៣០ (សាមសិប) ថ្ងៃ ៦០ (ហុកសិប) ថ្ងៃ និង ៩០ (កៅសិប) ថ្ងៃ ចាប់គិតពីថ្ងៃ បុគ្គលល្មើសទទួលបានលិខិតជូនដំណឹងអំពីការបង់ប្រាក់ពិន័យអន្តរកាណ៍ពី **ន.គ.ស.**

# ៧. បណ្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចពិន័យអន្តរការណ៍




✍ **ចំណាំ៖** បណ្ដឹងទៅតុលាការ ពុំមានអនុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេ។

# ៨. តម្លៃសេវាសាធារណៈ

| ល.រ | ប្រភេទសេវា | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | លិខិតអនុញ្ញាតផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ | ១, ០០០,០០០ | ៣០ ថ្ងៃ | រហូតដល់មានការអនុញ្ញាតថ្មី |
| ២ | លិខិតអនុញ្ញាតបដិប្បញ្ញត្តិដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១, ០០០,០០០ | ៣០ ថ្ងៃ | តែ ១ លើក |
| ៣ | លិខិតស្នើសុំពន្យារការបញ្ចប់ការងារសវនកម្មឯករាជ្យ | ២០០,០០០ | ១៥ ថ្ងៃ | តែ ១ លើក |
| ៤ | លិខិតសុំបញ្ជាក់បច្ចុប្បន្នភាពព័ត៌មានអង្គភាព | ២០០,០០០ | ៣០ ថ្ងៃ | ១លើក |

# ៨. តម្លៃសេវាសាធារណៈ (ត)

| ល.រ | ប្រភេទសេវា | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៤ | **សេវាទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ** | | | |
| | ៤.១ អង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់របាយ-ការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១០០,០០០ | ៣០ ថ្ងៃ | ១ ឆ្នាំ |
| | ៤.២ អង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់របាយ-ការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ៦០,០០០ | ៣០ ថ្ងៃ | ១ ឆ្នាំ |

# ប្រព័ន្ធផ្សព្វផ្សាយរបស់និយ័តករគណនេយ្យនិងសវនកម្ម




facebook.com/acarcambodia




https://www.acar.gov.kh/

# ប្រព័ន្ធផ្សព្វផ្សាយរបស់និយ័តករគណនេយ្យនិងសវនកម្ម

@NGO_ACARCAMBODIA

ព័ត៌មានអំពី NGO ពី ន.គ.ស

@ACARCAMBODIA

ព័ត៌មានគណនេយ្យនិងសវនកម្ម កម្ពុជា

# សូមអរគុណ